## កម្មវិធី Title I, Part A នៃច្បាប់ ស្តីពីសិស្សម្នាក់ៗសម្រេចបានជោគជ័យ (the Every Student Succeeds Act (ESSA))

ផ្តល់ជំនួយហិរញ្ញវត្ថុដល់រដ្ឋ និងទីភ្នាក់ងារអប់រំមូលដ្ឋាន (LEAs) ដើម្បីបំពេញតម្រូវការអប់រំរបស់សិស្ស ។ ការជួយគាំទ្រផ្នែកសិក្សាបន្ថែមទាំងនេះ ជួយដល់សិស្សានុសិស្សក្នុងការបំពេញតាមស្តង់ដារសិក្សារបស់រដ្ឋដែលមានការប្រកួតប្រជែង និងការបិទគម្លាតឱកាសសិក្សា ។



*ការស្រាវជ្រាវបានបង្ហាញថា នៅពេលសាលារៀន ក្រុមគ្រួសារ និងក្រុមការងារសហគមន៍ធ្វើការជាមួយគ្នាដើម្បីគាំទ្រការសិក្សានោះ កុមារៗហាក់ដូចជាធ្វើបានល្អប្រសើរនៅសាលារៀន ស្ថិតនៅសាលារៀនបានយូរជាង និងចូលចិត្តសាលារៀនច្រើនជាង ។*


**ការិយាល័យកម្មវិធី Title I, Part A Office**
Office of Superintendent of Public Instruction
Old Capitol Building
PO Box 47200
Olympia, WA 98504-7200
360-725-6100

**ក្រសួងអប់រំសហរដ្ឋអាមេរិក**
U.S. Department of Education
1-800-USA-LEARN (872-5327)



OSPI ផ្តល់ជូនការទទួលបានស្មើៗគ្នាចំពោះកម្មវិធី និងសេវាកម្មទាំងអស់ ដោយគ្មានការរើសអើងដោយផ្អែកលើភេទ ជាតិសាសន៍ លទ្ធិជំនឿ សាសនា ពណ៌សម្បុរ ប្រភពដើមជនជាតិ ដើមកំណើតជាតិសាសន៍ អាយុ អតីតយុទ្ធជនដែលរំសាយដោយកិត្តិយស ឬស្ថានភាពយោធា ទំនោរផ្លូវភេទ រួមទាំងការបង្ហាញឬអត្តសញ្ញាណយេនឌ័រការបង្ហាញវត្តមានពិការភាពខាងវិញ្ញាណ ផ្លូវចិត្ត ឬរាងកាយ ឬការប្រើប្រាស់ការនាំផ្លូវដោយសត្វឆ្កែដែលបានបង្ហាត់បង្រៀន ឬការប្រើសត្វបម្រើឱ្យបុគ្គលដែលមានភាពពិការ ។ សំណួរ និងពាក្យបណ្តឹងអំពីការរើសអើងដែលបានចោទប្រកាន់ ត្រូវបញ្ជូនដោយផ្ទាល់ទៅនាយកផ្នែកសមភាព និងសិទ្ធិជនស៊ីវិល តាមលេខទូរស័ព្ទ៖ (360) 725-6162 ឬ P.O. Box 47200 Olympia, WA 98504-7200.


# មគ្គុទ្ទេសក៍គ្រួសារ

# តើកម្មវិធី Title I, Part A ជាអ្វី?




ការិយាល័យនាយកអប់រំសាធារណៈ
នាយកដ្ឋានកម្មវិធី TitleI/LAP

## តើកម្មវិធី Title I, Part A បម្រើសេវាកម្មនៅសាលាណាខ្លះ?

កម្មវិធីនេះបម្រើដល់សិស្សានុសិស្សក្នុងការសិក្សាដំបូង កម្មវិធីសាលាបង្រៀនកុមារមិនទាន់គ្រប់អាយុចូលរៀន និងមត្តេយ្យសាលាដល់វិទ្យាល័យ ដែលបានបង្ហាញពីតម្រូវការសម្រាប់ជំនួយផ្នែកអប់រំបន្ថែម ។ សេវាកម្មនៃកម្មវិធី Title I, Part A អាចមានសម្រាប់សិស្សានុសិស្សដែលមានសិទ្ធិចូលរៀនសាលាឯកជន ដែលបានស្នើសុំចូលរួមក្នុងកម្មវិធី Title I, Part A ។

## តើកម្មវិធី Title I, Part A នឹងផ្តល់ជូនកូនខ្ញុំអ្វីខ្លះ?

កម្មវិធី Title I, Part A គឺជាកម្មវិធីសហព័ន្ធដែលផ្តល់ជូនសេវាកម្ម និងសកម្មភាពបង្រៀនបន្ថែម ។ ការជួយគាំទ្រផ្នែកសិក្សាបន្ថែមទាំងនេះ ជួយដល់សិស្សានុសិស្សក្នុងការបំពេញតាមស្តង់ដារសិក្សារបស់រដ្ឋដែលមានការប្រកួតប្រជែង និងការបិទគម្លាតឱកាសសិក្សា ។

**ជំនួយបង្រៀនបន្ថែម អាចមាន៖**

- សម្ភារៈបង្រៀនដែលបំពេញបន្ថែមការបង្រៀនជាធម្មតារបស់សិស្សានុសិស្ស
- គ្រូបង្រៀន និងអ្នកជួយការបង្រៀន
- ការបង្រៀនសិស្សម្នាក់ ឬការបង្រៀនជាក្រុមតូចៗ
- ការជួយគាំទ្រផ្នែកសិក្សាបន្ថែម

## មាតាបិតា និងគ្រួសារ

លោកអ្នកអាចជួយកូនអ្នកឱ្យបានជោគជ័យតាមរយៈការចូលរួមយ៉ាងសកម្មនៅសាលារបស់កូនអ្នក៖

- ✓ **ប្រាស្រ័យទាក់ទង៖** បការរក្សាផ្តល់ជូនព័ត៌មាន និងការឆ្លើយតបភ្លាមៗចំពោះប្រាស្រ័យទាក់ទងទាំងអស់ពីសាលារៀន ឬមណ្ឌលសិក្សាធិការ ។
- ✓ **ធ្វើជាឧទាហរណ៍៖** ការបង្ហាញកូនរបស់អ្នកថា ការអប់រំមានសារៈសំខាន់តាមរយៈការអាន ការចូលរួមកិច្ចប្រជុំមាតាបិតា/គ្រូបង្រៀន និងការចូលរួមនៅតាម "ផ្ទះដោយស្វាគមន៍" ។
- ✓ **ស្ម័គ្រចិត្ត៖** ការស្ម័គ្រចិត្តនៅសាលារៀនកូនរបស់អ្នក និងការជួយសកម្មភាពក្រៅកម្មវិធីសិក្សា ។ ចូលរួម និងជួយគាំទ្រសកម្មភាពដែលចូលរួមដោយមាតាឬបិតានៅសាលារៀន ។
- ✓ **សិក្សា៖** របៀបជួយកូនរបស់អ្នកចំពោះកិច្ចការនៅថ្នាក់រៀន ការធ្វើលំហាត់នៅផ្ទះ និងផែនការអប់រំនាពេលអនាគត ។
- ✓ **ចូលរួម៖** អង្គការសាលារៀន/មាតាឬបិតារួមគ្នា ក្រុមការងារធ្វើឱ្យប្រសើរឡើងនៅសាលារៀន ក្រុមប្រឹក្សាផ្នែកផ្តល់ប្រឹក្សាមាតាបិតានៃកម្មវិធី Title I, Part A និងគណៈកម្មការមាតាបិតាផ្សេងទៀត ។
- ✓ **សហការជាមួយសហគមន៍៖** ការចូលរួមក្នុងសកម្មភាពមាតាឬបិតាជាមួយក្រុមគ្រួសារដទៃទៀត យល់ដឹងនិងប្រើប្រាស់ធនធានសហគមន៍មូលដ្ឋាន ដូចជាបណ្ណាល័យ សាកលវិទ្យាល័យ មជ្ឈមណ្ឌលសហគមន៍ជាដើម ដើម្បីបង្កើនជំនាញនិងទេពកោសល្យ ដើម្បីទទួលបានសេវាកម្មតាមតម្រូវការចាំបាច់សម្រាប់កូនរបស់អ្នក ។



## តើសាលាទទួលបានថវិកាកម្មវិធី Title I, Part A តាមរបៀបណា?

- ទីមួយ រដ្ឋាភិបាលសហព័ន្ធផ្តល់ថវិកាដល់រដ្ឋនីមួយៗ ដោយផ្អែកលើទិន្នន័យជំរឿនប្រជាពលរដ្ឋ ។ បន្ទាប់មកទីភ្នាក់ងារអប់រំថ្នាក់រដ្ឋនីមួយៗ (SEA) នឹងផ្តល់ប្រាក់ដល់ទីភ្នាក់ងារអប់រំមូលដ្ឋាន (LEAs) របស់ខ្លួន ។ ទីភ្នាក់ងារ LEAs កំណត់សាលារៀននានាដែលមានសិទ្ធិទទួលបានមូលនិធិនៃកម្មវិធី Title I, Part A ដោយគោរពតាមវិធាននានានៃកម្មវិធី ESSA Title I Part A ។
- ចំណុចចុងក្រោយទីភ្នាក់ងារ LEA នីមួយៗកំណត់ថា តើសាលារៀនរបស់ពួកគេ នឹងទទួលបានសេវាកម្មនានានៃកម្មវិធី Title I, Part A ឬទេ ដោយផ្អែកលើភាគរយអាហារថ្ងៃត្រង់ឥតគិតថ្លៃ និងអាហារថ្ងៃត្រង់ចុះថ្លៃនៅសាលារៀន ។ បន្ទាប់មកសាលានឹង៖

1. កំណត់អត្តសញ្ញាណសិស្សានុសិស្សដែលត្រូវការជំនួយផ្នែកអប់រំបន្ថែម ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលតម្រូវឱ្យមាន ។ សិស្សានុសិស្ស មិនត្រូវមកពីគ្រួសារដែលមានប្រាក់ចំណូលទាប ដើម្បីទទួលបានសេវាកម្មនានានៃកម្មវិធី Title I, Part A ឡើយ ។
2. កំណត់គោលដៅនានាសម្រាប់ការធ្វើឱ្យប្រសើរឡើងជំនាញសិស្សានុសិស្សដែលជួបការលំបាកខាងការសិក្សានៅសាលារៀនរបស់ពួកគេ ។
3. រៀបចំកម្មវិធីសម្រាប់សិស្សានុសិស្សម្នាក់ៗដើម្បីជួយគាំទ្រ/បំពេញបន្ថែមការបង្រៀនតាមថ្នាក់រៀនធម្មតា ។
4. វាស់ស្ទង់ដំណើរការរីកច្រើនរបស់សិស្សានុសិស្ស ដើម្បីកំណត់ពីភាពជោគជ័យនៃកម្មវិធី Title I, Part A សម្រាប់សិស្សានុសិស្សម្នាក់ៗ ។

**សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធី Title I, Part A សូមពិគ្រោះយោបល់ជាមួយយើងខ្ញុំតាមអនឡាញតាម៖ http://www.k12.wa.us/TitleI**